ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាព
# សម្រាប់
# ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩
# លើកុមារ-យុវវ័យអាយុពី១២ឆ្នាំទៅក្រោម១៨ឆ្នាំ

រៀបចំដោយ

**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**

ខែកក្កដា ឆ្នាំ២០២១

# អារម្ភកថា

ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ បាននាំមកនូវគ្រោះមហន្តរាយដល់ពិភពលោកទាំងមូល ដោយសារជំងឺដ៏កាចសាហាវនេះបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សុខភាពមនុស្សជាតិ, ប្រព័ន្ធសុខាភិបាល និងសង្គម-សេដ្ឋកិច្ច។ ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបជាបន្តបន្ទាប់ ដើម្បីបង្ការ, កាត់បន្ថយ និងទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺនេះ នៅក្នុងសហគមន៍ សំដៅកាត់បន្ថយផលប៉ះពាល់មកលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងធានាបាននូវការបើកដំណើរការពេញលេញ និងជាបណ្ដើរៗ នៃសកម្មភាពសង្គម-សេដ្ឋកិច្ច។ ក្នុងចំណោមយុទ្ធសាស្ត្រទាំងនោះ **ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩** ត្រូវបានចាត់ទុកថា ជាវិធានការយុទ្ធសាស្ត្រគន្លឹះមួយ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់ផ្ដាច់ការបន្តឆ្លងរាតត្បាត តាមរយៈការកាត់បន្ថយករណីឆ្លង និងករណីឈឺធ្ងន់ធ្ងរ ព្រមទាំងក្នុងការការពារ និងការជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋកម្ពុជាគ្រប់រូប សម្រាប់ពេលបច្ចុប្បន្នផង និងត្រៀមលក្ខណៈសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាពជាមួយវត្តមាននៃមេរោគកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

**យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩** ដែលបានចាប់ផ្ដើមកាលពីថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២១ រហូតមកដល់ពេលនេះ (គិតត្រឹមថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២១) កំពុងស្ថិតនៅលើមាគ៌ាវឌ្ឍនភាពដ៏ល្អប្រសើរ ដោយសម្រេចបានប្រមាណ ៧០,៤៤% នៃប្រជាពលរដ្ឋគោលដៅ អាយុចាប់ពី១៨ឆ្នាំឡើង ដែលមានចំនួន ១០លាននាក់ ឬប្រមាណ ៤៤% នៃប្រជាជនសរុប។

យោងតាមអង្គការសុខភាពពិភពលោក ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ល្អបំផុតគឺត្រូវសម្រេចឱ្យបានការចាក់វ៉ាក់សាំងដែលគ្របដណ្ដប់បាន លើសពី៩០% នៃចំនួនប្រជាជនសរុប។ ចំនួននេះនឹងអនុញ្ញាតឱ្យប្រទេសនីមួយៗអាចទប់ទល់ជាមួយមេរោគកូវីដ-១៩ បំលែងខ្លួន ដូចជាប្រភេទដែលតាជាដើម។ ជាមួយគ្នានេះ អង្គការ GAVI (Global Alliance for Vaccination and Immunization) បានលើកឡើងថាដើម្បីឱ្យពិភពលោកទាំងមូលប្រកបដោយសុវត្ថិភាពពេញលេញ មនុស្សគ្រប់រូបត្រូវទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយរាប់បញ្ចូលទាំងកុមារ និងយុវវ័យ ផងដែរ។ ក្នុងន័យនេះ ស្របពេលនៃកិច្ចដំណើរការនៃយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើង ប្រទេសកម្ពុជា ក៏បាន និងកំពុងរៀបចំផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ អាយុពី១២ឆ្នាំទៅក្រោម១៨ឆ្នាំ ដែលមានចំនួនប្រមាណ ២លាននាក់បន្ថែមទៀត។

ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងនេះ នឹងក្លាយជាកាលានុវត្តភាពថ្មីមួយទៀត សម្រាប់រាជរដ្ឋាភិបាលក្នុងការពង្រីកវិសាលភាពគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើប្រជាពលរដ្ឋឱ្យបានកាន់តែច្រើនថែមទៀត ដើម្បីបង្កើនការការពារអាយុជីវិតប្រជាពលរដ្ឋ និងឈានឆ្ពោះទៅបង្កើតភាពស៊ាំសហគមន៍នៅទូទាំងកម្ពុជាទាំងមូល។ ការសម្រេចចិត្តក្នុងការចាក់វ៉ាក់សាំងជូនកុមារ និងយុវវ័យនេះ មិនមែនជាការសម្រេចចិត្តដោយចៃដន្យនោះទេ ព្រោះក្រៅពីគុណប្រយោជន៍ដែលទទួលបាន ដូចការបញ្ជាក់របស់អង្គការសុខភាពពិភពលោក រាជរដ្ឋាភិបាលកម្ពុជា បានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះយុទ្ធនាការចាក់វ៉ាក់សាំងលើកុមារ និងយុវវ័យ ដែលកំពុងត្រូវបាន ឬគ្រោងអនុវត្ត នៅតាមបណ្តាប្រទេសជាច្រើននៅលើពិភពលោក ដូចជា ប្រទេសចិន, សហរដ្ឋអាមេរិក, បណ្តាប្រទេសនៅទ្វីបអឺរ៉ុប ដូចជា អង់គ្លេស និងបារាំង និងបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិកដូចជា ជប៉ុន, ហុងកុង, សិង្ហបុរី, ឥណ្ឌូនេស៊ី និងហ្វីលីពីន ជាដើម។

ការដាក់ចេញឱ្យអនុវត្តនូវ **ផែនការសកម្មភាព សម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យអាយុពី១២ឆ្នាំទៅក្រោម១៨ឆ្នាំ** សំដៅបង្ការ និងទប់ស្កាត់ការចម្លងនៃជំងឺកូវីដ-១៩ នៅក្នុងចំណោមកុមារ-យុវវ័យ ព្រមទាំងកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ ឬការបាត់បង់អាយុជីវិត ដែលបណ្តាលមកពីជំងឺកូវីដ-១៩។ លើសពីនេះទៀត ការវ៉ាក់សាំងអាចជួយការពារដល់កុមារ-យុវវ័យ ពីផលប៉ះពាល់អវិជ្ជមាននៃការលូតលាស់ផ្នែកស្មារតី និងរាងកាយ ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ដោយជួយកុមារ-យុវវ័យឱ្យវិលត្រឡប់មករស់នៅប្រកបដោយសុវត្ថិភាពតាមគន្លងប្រក្រតីភាពថ្មី ជាពិសេសការវិលត្រឡប់ទៅកាន់សាលារៀនវិញ ការជួបជុំមិត្តភក្តិ ការចូលរួមកម្មវិធីសំខាន់ៗ ដូចជាការហាត់ប្រាណ ការលេងកីឡា និងការប្រគុំតន្ត្រី ជាដើម ដែលសុទ្ធតែជាសកម្មភាពសំខាន់ និងចាំបាច់ ក្នុងការរួមចំណែក ដល់ការលូតលាស់ផ្នែកប្រាជ្ញាស្មារតី ផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាពរបស់កុមារ-យុវវ័យ។

ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលបានដឹកនាំ និងរៀបចំចាត់ចែងយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងសូមសំដែងនូវការកោតសរសើរចំពោះអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ព្រមទាំងគ្រូពេទ្យ បុគ្គលិកសុខាភិបាលទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការកូវីដ១៩ ជូនប្រជាពលរដ្ឋកម្ពុជា។ ទន្ទឹមគ្នានេះ ខ្ញុំសូមសូមវាយតម្លៃខ្ពស់ចំពោះក្រុមការងារនៃអនុគណៈកម្មការផែនការនិងថវិកានីយកម្ម នៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលបានរៀបចំ **ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-**

**យុវវ័យអាយុពី១២ឆ្នាំទៅក្រោម១៨ឆ្នាំ** ដ៏សំខាន់នេះ និងចំពោះអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ដែលបានផ្តល់យោបល់និងកិច្ចសហការក្នុងការរៀបចំឯកសារផែនការនេះ។

ខ្ញុំសូមណែនាំឱ្យគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត អនុវត្ត **ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យអាយុពី១២ឆ្នាំទៅក្រោម១៨ឆ្នាំ** ប្រកបដោយស្មារតីទទួលខុសត្រូវ និងទទួលបានប្រសិទ្ធភាពខ្ពស់ ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់កុមារ-យុវវ័យកម្ពុជាគ្រប់រូប ដែលនឹងក្លាយជាទំពាំងឫស្សី និងជាសសរទ្រូងប្រទេសជាតិប្រកបដោយភាពរឹងមាំ ជាពិសេសប្រកបដោយសុខភាពបរិបូណ៌ និងបញ្ញាស្មារតីភ្លឺថ្លា ។

ថ្ងៃ សុក្រ ៦រោច ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


1. សេចក្តីផ្តើម ........ 1

1.1 សារៈបាន ........ 1

1.2 សន្និទានកម្ម ........ 2

1.3 បញ្ហាប្រឈម និងភាពលានុវត្តភាព ........ 4

2. គោលបំណង និងគោលដៅ ........ 7

2.1. គោលបំណង ........ 7

2.2. គោលដៅ ........ 7

2.3. គោលការណ៍នៃចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ........ 7

3. អភិក្រមនៃការចាក់វ៉ាក់សាំង ........ 10

3.1 វិធីសាស្រ្តចម្រុះបត់បែន ........ 10

3.2 នីតិវិធីដើម្បីទទួលបានការចាក់វ៉ាក់សាំង ........ 11

3.3 ការកំណត់ និងការរៀបចំទីតាំងចាក់វ៉ាក់សាំង ........ 12

3.4 ក្រុមការងារចាក់វ៉ាក់សាំង ........ 13

3.5 ការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ........ 13

3.6 ការគ្រប់គ្រងវ៉ាក់សាំង និងសំណល់ក្រោយការចាក់វ៉ាក់សាំង ........ 14

3.8 ការពិនិត្យតាមដាននិងវាយតម្លៃការងារចាក់វ៉ាក់សាំង ........ 15

4. ការអនុវត្តផែនការចាក់វ៉ាក់សាំងតាមជំហាន ........ 16

4.1. ការប៉ាន់ស្មានអំពីចំនួនវ៉ាក់សាំងនិងរយៈពេលដែលត្រូវការ ........ 16

4.2. ជំហាននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ........ 16

# 1. សេចក្តីផ្តើម

## 1.1 សារបាន

ប្រទេសកម្ពុជាបានចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ជុំទី១ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ លើប្រជាពលរដ្ឋអាយុពី១៨ឆ្នាំឡើង សម្រាប់គោលដៅ ១០លាននាក់ តាមរយៈការអនុវត្ត «ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស» (ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១) និង «ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា» (ខែឧសភា ឆ្នាំ២០២១)។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក) **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន គ.ប.ក បានដាក់ចេញនូវយុទ្ធសាស្ត្រ ចំនួន ៦ សម្រាប់ឆ្លើយតបនឹងស្ថានភាពចំពោះមុខផង និងត្រៀមលក្ខណៈសម្រាប់ពេលខាងមុខផង ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងនោះយុទ្ធសាស្ត្រ ទី៦ ផ្តោតលើការពន្លឿនយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ជុំទីមួយ និងការត្រៀមលក្ខណៈផ្តល់វ៉ាក់-សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋដែលមានអាយុក្រោម១៨ឆ្នាំ បន្ថែមទៀត។

នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២១ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងសារបញ្ជាក់អំពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យដែលមានអាយុពី១២ឆ្នាំទៅក្រោម ១៨ឆ្នាំ (កុមារ-យុវវ័យ)។ សារនេះបានបង្ហាញអំពីឆន្ទៈនយោបាយដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការការពារអាយុជីវិតប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ចំពោះមុខស្ថានភាពនៃការចម្លងនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្នផង និងការបង្កើតនូវបរិយាកាសប្រកបដោយទំនុកចិត្តផង សម្រាប់ការបើកដំណើរឡើងវិញជាបណ្តើរៗ នូវសកម្មភាពសង្គមសេដ្ឋកិច្ច ឆ្ពោះទៅកាន់ការបើកប្រទេសពេញលេញឡើងវិញ និងការរស់នៅប្រកបដោយ សុវត្ថិភាពរបស់ប្រជាពលរដ្ឋ ជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

គិតត្រឹម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ប្រទេសកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ដល់ប្រជាពលរដ្ឋដែលមានអាយុពី១៨ឆ្នាំឡើង បានចំនួន ៧.០៤៣.៩៦៩នាក់ ឬស្មើនឹង ៧០,៤៤% និងដូសទី២ បាន ៤.៦២៦.៦៤៨នាក់ ឬស្មើនឹង ៤៦,២៦% នៃប្រជាពលរដ្ឋគោលដៅ ១០លាននាក់។ គួរកត់សម្គាល់ថា ០,៩៥% នៃប្រជាពលរដ្ឋ ៧.០៤៣.៩៦៩នាក់ ដែលបានស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនត្រូវបានគ្រូពេទ្យអនុញ្ញាតឱ្យចាក់វ៉ាក់សាំង ដោយសារបញ្ហាសុខភាពផ្ទាល់ខ្លួន។ រីឯផលរំខានដែលបានកើតឡើងក្រោយពេលចាក់វ៉ាក់សាំងមានចំនួន ១៥៥ករណី ក្នុង

ចំណោម វ៉ាក់សាំងដែលបានចាក់សរុប ៥.៧៩៦.១៦៤ដូស (សរុបដូសទី១ និងដូសទី២) ឬក្នុងអត្រា ២ ករណី ផលវិបាក ក្នុងវ៉ាក់សាំង ១០០.០០០ ដូស គិតត្រឹមថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២១ ។

ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទីមួយ គ្រោងនឹងបញ្ចប់នៅក្នុងខែវិច្ឆិកាខាងមុខនេះ ខណៈនោះប្រទេសកម្ពុជានឹងសម្រេចការគ្របដណ្ដប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ប្រមាណ ៦២% នៃចំនួនប្រជាជនកម្ពុជាសរុបទូទាំងប្រទេស(ប្រមាណ១៦លាននាក់)។ ដូច្នេះការពង្រីកវិសាលភាពនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទីពីរ លើកុមារនិងយុវវ័យអាយុពី១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ (បន្ទាប់ទៅនេះហៅថា កុមារ-យុវវ័យ) ដែលមានចំនួនប្រមាណ ២ លាននាក់បន្ថែមទៀត នឹងបង្កើនការគ្របដណ្ដប់នៃវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ អាចរហូតដល់ ៧៥% នៃប្រជាពលរដ្ឋសរុប។

## 1.2 សន្និដ្ឋានកម្ម

និន្នាការនៃការចម្លងជំងឺកូវីដ-១៩ ក្រោយ "ព្រឹត្តការណ៍សហគមន៍ ២០ កុម្ភៈ" រហូតមកដល់ពេលនេះ កំពុងស្ថិតនៅក្នុងភាពសកម្ម ដោយហេតុថា នៅក្នុងរយៈពេលពីរសប្ដាហ៍ចុងក្រោយ (ពីថ្ងៃទី០៧ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១) ចំនួនករណីថ្មីប្រចាំថ្ងៃនៃជំងឺកូវីដ-១៩ ដែលបានរកឃើញ និងអត្រាតេស្តវិជ្ជមានមេរោគកូវីដ-១៩ នៅមិនទាន់ចុះទាប ព្រមជាមួយគ្នានេះ អត្រាស្លាប់ដែលបណ្ដាលមកពីជំងឺកូវីដ-១៩ ក៏នៅមានកម្រិតខ្ពស់នៅឡើយ។ ម្យ៉ាងវិញទៀត មេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មីប្រភេទដែលតាត្រូវបានរកឃើញក្នុងសហគមន៍នាពេលថ្មីៗ នេះ។

ទោះបីជាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនអាចផ្ដាច់ការចម្លងបានទាំងស្រុងក៏ដោយ ក៏ការចាក់វ៉ាក់សាំងពេញលេញត្រូវបានរំពឹងទុកថា ជួយកាត់បន្ថយការឆ្លងបានមួយកម្រិត ដោយសារវ៉ាក់សាំងបានបង្កើតអង្គបដិបក្ខ(Antibody)ប្រឆាំងនឹងមេរោគកូវីដ-១៩ នៅក្នុងខ្លួនបុគ្គលបានចាក់វ៉ាក់សាំងដែលអាចកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ និងការសម្រាកព្យាបាលនៅមន្ទីរពេទ្យ យោងតាមរបកគំហើញនៃការសិក្សាអំពីប្រសិទ្ធភាពនៃវ៉ាក់សាំង ពីបណ្ដាប្រទេសមួយចំនួន។ អង្គការសុខភាពពិភពលោកបានផ្ដល់អនុសាសន៍ថាជាការល្អបំផុតត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានលើសពី ៩០% នៃចំនួនប្រជាជនដើម្បីទប់ទល់ជាមួយមេរោគកូវីដ-១៩ បំលែងខ្លួន ដូចជាប្រភេទដែលតាជាដើម។ ជាមួយគ្នានេះ អង្គការ GAVI (Global Alliance for Vaccination and Immunization) បានលើកឡើងថាដើម្បីឱ្យពិភពលោកមានសុវត្ថិភាព មនុស្សគ្រប់រូបត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយរាប់បញ្ចូលទាំងកុមារផងដែរ។

គួរកត់សម្គាល់ថា បើយោងតាមឯកសារស្រាវជ្រាវ រហូតមកដល់ពេលនេះមានប្រទេសជាច្រើននៅក្នុងពិភពលោកបាននិងកំពុងដំណើរការ ឬត្រៀមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩លើកុមារ-យុវវ័យដោយ-សារហេតុផលសំខាន់ៗ មួយចំនួនៈ

- **បញ្ឈប់ការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩៖** កុមារជាក្រុមប្រជាជនភាគច្រើន ក្នុងចំណោមប្រជាជនទាំងអស់ ហើយវ៉ាក់សាំងនឹងកាន់តែមានប្រសិទ្ធភាព កាលណាប្រជាជនកាន់ច្រើនបានចាក់វ៉ាក់សាំង។
- **កុមារមិនមានភាពស៊ាំប្រឆាំងមេរោគកូវីដ-១៩ ទេ៖** ជាការសង្កេតទូទៅ កុមារកម្រឈឺធ្ងន់ ប៉ុន្តែការឆ្លងជំងឺកូវីដ-១៩ អាចធ្វើឱ្យកុមារឈឺធ្ងន់ធ្ងរបាន។ ដូច្នេះវ៉ាក់សាំងអាចការពារកុមារពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ក្នុងរយៈពេលខ្លីផង និងយូរអង្វែងផង។
- **ជីវិតអាចវិលត្រឡប់មករកប្រក្រតីភាពតាមបែបគន្លងថ្មី៖** ការចាក់វ៉ាក់សាំង គឺជាមធ្យោបាយមួយ ដែលជួយសហគមន៍ឱ្យវិលត្រឡប់មករស់នៅប្រកបដោយសុវត្ថិភាពតាមគន្លងប្រក្រតីភាពថ្មី។ ក្មេងៗ និងវ័យជំទង់ កំពុងបាត់បង់ឱកាសចូលរួមសកម្មភាពជាច្រើននៃជីវិតរបស់ពួកគេ ដូចជា ការសិក្សា, ការជួបជុំមិត្តភក្តិ, លេងកីឡា, ការប្រគុំតន្ត្រី និងកំសាន្តនៅសាលារៀនជាដើម។

| ប្រទេស | ហេតុផលនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩លើកុមារ-យុវវ័យ |
|---|---|
| **បែលហ្ស៊ិក និង ដាណឺម៉ាក** | • រួមចំណែកបង្កើនអត្រាទទួលបានវ៉ាក់សាំងក្នុងប្រជាជនទូទៅ ដើម្បីសម្រេចបានភាពស៊ាំក្នុងសហគមន៍ |
| **កាណាដា** | • កាត់បន្ថយការរាលដាលនៃការចម្លងមេរោគកូវីដ-១៩ពីមនុស្សម្នាក់ទៅម្នាក់ទៀត និងជួយគ្រប់គ្រងការរាតត្បាតជាសកល ដោយបញ្ឈប់ការចម្លងក្នុងរង្វង់ក្រុមមនុស្សវ័យជំទង់ |
| **ប្រទេសចិន និងដែនដីហុងកុង** | • បង្កើនអត្រាចាក់វ៉ាក់សាំង ដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍ |
| **ឈីលី** | • បង្កើនអត្រាគ្របដណ្តប់នៃការទទួលបានវ៉ាក់សាំង |
| **ឥណ្ឌូនេស៊ី** | • កាត់បន្ថយអត្រាមរណភាពកុមារ បណ្តាលមកពីការកើនឡើងករណីកូវីដ-១៩ យ៉ាងគំហុក |
| **ហ្វាំងឡង់** | • ផ្តល់អាទិភាពទី១ ដល់ក្មេងៗ ដែលមានហានិភ័យខ្ពស់ ដើម្បីកាត់បន្ថយហានិភ័យនៃការឈឺ និងស្លាប់<br>• ចូលរួមបំពេញបន្ថែម សម្រេចគោលដៅចម្បងនៃការចាក់វ៉ាក់សាំង រួមមាន៖ បន្ថយភាពធ្ងន់ធ្ងរនៃជំងឺបណ្តាលមកពីកូវីដ-១៩ ស្លាប់មុនអាយុ ការពារដំណើរការមុខងារនៃប្រព័ន្ធសុខាភិបាល<br>• បន្ធូរបន្ថយការរឹតបន្តឹងលើសកម្មភាពកុមារ ដូចជាការជួបជុំគ្នា សកម្មភាពកំសាន្ត ទៅសាលារៀន ដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខមាលភាពកុមារ |
| **អេស្ប៉ាញនិង** | • ការពារក្មេងៗពីការឆ្លងវីរុសក្សូ័ណាបំប្លែងខ្លួនប្រភេទដែលតា |

| | | |
|---|---|---|
| **អ៊ីស្រាអ៊ែល** | • | ធ្លាប់មានបទពិសោធន៍នៃឆ្លងយ៉ាងគំហុកក្នុងចំណោមប្រជាជនវ័យក្មេង |
| | • | ការពារកុំឱ្យមានការឆ្លងរាលដាលដល់ក្រុមវ័យចំណាស់ និងក្រុមប្រជាជនមានហានិភ័យខ្ពស់ |
| **ណូវែលហ្សេឡង់** | • | ក្មេងៗអាចចម្លងមេរោគទៅក្រុមប្រជាជនមានហានិភ័យខ្ពស់ និងក្រុមមនុស្សដែលមិនអាចទទួលវ៉ាក់សាំងដោយសារមូលហេតុសុខភាព |
| | • | ការពារក្មេងៗ ពីបញ្ហាសុខភាពរយៈពេលយូរអង្វែង |
| **ម៉ាល់តា** | • | ក្នុងគ្រួសាររស់នៅជិតស្និទ្ធជាមួយគ្នា ការចាក់វ៉ាក់សាំងឱ្យក្មេងៗគឺជាការចាំបាច់ដើម្បីការពារមនុស្សចាស់ក្នុងគ្រួសារ |
| | • | ក្មេងៗ ជារឿយៗ សិក្សានៅបរទេស ដូច្នេះការចាក់វ៉ាក់សាំងឱ្យពួកគេអាចជួយការពារការនាំវីរុសបំប្លែងខ្លួនប្រភេទថ្មីចូលក្នុងប្រទេស |

## 1.3 បញ្ហាប្រឈម និងកាលានុវត្តភាព

ផ្អែកតាមវាយតម្លៃខាងលើ បើសិនស្ថានភាពនៃការចម្លងបច្ចុប្បន្នមិនអាចកាត់បន្ថយ និងទប់ស្កាត់បាន រួមទាំងការទប់ស្កាត់មេរោគដែលតាផង នោះការឆ្លងរាតត្បាតអាចឈានទៅកាន់ការឆ្លងសហគមន៍ទ្រង់ទ្រាយធំ ដែលនឹងនាំមកនូវគ្រោះមហន្តរាយដល់ប្រទេសជាតិ ទាំងផ្នែកសង្គម-សេដ្ឋកិច្ច ទាំងផ្នែកសុខភាពសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសមនុស្សចាស់ ក្រុមវ័យជំទង់និងកុមារ និងប៉ះពាល់ដល់យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងមូល និងនិយាយដោយឡែកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ។

### បញ្ហាប្រឈម

នៅចំពោះមុខហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន និងចរិតលក្ខណៈរបស់កុមារ កិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ ត្រូវបានរំពឹងទុកថានឹងប្រឈមជាមួយបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការប្រមូលផ្តុំមនុស្សច្រើន នៅក្នុងទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និមួយៗ ដោយសារមានទាំងកុមារ-យុវវ័យដែលត្រូវចាក់សាំងផង និងមាតា-បិតា ឬអាណាព្យាបាលដែលនាំកុមារ-យុវវ័យ ទាំងនោះទៅចាក់វ៉ាក់សាំងផងៗ ការណ៍នេះទាមទារឱ្យមានការរៀបចំទីតាំងឱ្យបានសមស្រប មានសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពខ្ពស់ ព្រមទាំងលើកកម្ពស់ការប្រុង-ប្រយ័ត្នជាប្រចាំ នៅក្នុងពេលដំណើរការចាក់វ៉ាក់សាំង។

- ផលរំខានក្រោយការចាក់វ៉ាក់សាំងដែលអាចកើតមានដោយថាហេតុ ភ្លាមៗឬក្រោយនោះបន្តិច អាចធ្វើឱ្យកុមារ-យុវវ័យតក់ស្លុត ជ្រួលច្របល់ បាត់បង់សណ្តាប់ធ្នាប់ ឬឈានទៅកាន់ភាពចលាចល នៅពេលដែលស្ថានការណ៍មិនអាចគ្រប់គ្រងបានឆាប់រហ័ស។

បើសិនទីតាំងចាក់វ៉ាក់សាំងនិមួយៗ មិនត្រូវបានត្រៀមលក្ខណៈម្ចាស់ការទុកជាមុន សម្រាប់ឆ្លើយតបបញ្ហាប្រឈមដែលអាចកើតមានខាងលើ ឱ្យបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាព កុមារ-យុវវ័យនឹងជក់ជាប់នូវអារម្មណ៍ភ័យខ្លាច ហើយមាតា-បិតា ឬអាណាព្យាបាលក៏អាចបាត់បង់ទំនុកចិត្ត ឬរារែកចិត្តក្នុងការនាំបុត្រធីតា ឬកូន-ក្មួយទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ។ ជាផលវិបាក ដំណើរការចាក់វ៉ាក់សាំងលើកុមារ-យុវវ័យ និងលើប្រជាជនអាយុពី១៨ឆ្នាំឡើង នឹងមិនអាចសម្រេចបានតាមផែនការ ទាំងក្នុងក្របខ័ណ្ឌពេលវេលា ទាំងអត្រាគ្របដណ្តប់នៃវ៉ាក់សាំង។

## កាលានុវត្តភាព

កិច្ចដំណើរការចាក់វ៉ាក់សាំងជុំទីមួយ បានផ្តល់នូវបទពិសោធន៍ជាក់ស្តែងគ្រប់គ្រាន់ដែលជាមូលដ្ឋានសម្រាប់ការត្រៀមលក្ខណៈឱ្យបានរួចរាល់ទុកជាមុន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានប្រមើលឃើញខាងលើ។ បទពិសោធន៍ទាំងនេះត្រូវបានចាត់ទុកថាជាកាលានុវត្តភាពមួយ ក្នុងចំណោមកាលានុ-វត្តភាពដទៃទៀត ដែលអំណោយផលដល់កិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩លើកុមារ-យុវវ័យ ឱ្យប្រព្រឹត្តទៅបានលឿន តាមដែលអាចធ្វើបាន រួមមានជាអាទិ៍ដូចខាងក្រោមនេះ៖

- ជាទូទៅប្រទេសកម្ពុជាមានពិសោធន៍ និងសមត្ថភាពខ្ពស់ ក្នុងការផ្តល់វ៉ាក់សាំងបង្ការជំងឺដល់កុមារ តាមរយៈកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។
- ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី១ បាន និងកំពុងប្រព្រឹត្តទៅតាមផែនការដែលគ្រោងទុក ដោយឡែករាជធានីភ្នំពេញ និងខេត្តកណ្តាលបានសម្រេចគោលដៅជុំទី១ នៅក្នុងខែមិថុនាកន្លងទៅនេះ ខណៈដែលបណ្តាខេត្តផ្សេងទៀតកំពុងបង្កើនល្បឿននៃការចាក់វ៉ាក់សាំងជុំទី១។
- ស្ថានភាពនៃការឆ្លងរាតត្បាតបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងបាន ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងការឆ្លងនៃមេរោគដែលនាំចូលទៅក្នុងសហគមន៍។
- អត្រាឆ្លងជំងឺកូវីដ-១៩ លើប្រជាជនអាយុក្រោម៩ឆ្នាំ និងពី១០-១៩ឆ្នាំ នៅមានកម្រិតទាបណាស់ បើប្រៀបធៀបនឹងប្រជាជនអាយុពី២០ឆ្នាំ ឡើង។
- រាជរដ្ឋាភិបាលបានត្រៀមបម្រុងរួចជាស្រេចនូវបរិមាណវ៉ាក់សាំងគ្រប់គ្រាន់ សម្រាប់ចាក់លើកុមារ-យុវវ័យ។

- ប្រព័ន្ធ យន្តការ និងសេវាគាំទ្រចាំបាច់នានា ដែលកំពុងដំណើរសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទីមួយ ព្រមទាំងធនធានមនុស្ស បានផ្តល់នូវមូលដ្ឋានគ្រឹះ ទាំងផ្នែកបច្ចេកទេស និងភស្តុភារសម្រាប់ដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ។

# 2. គោលបំណង និងគោលដៅ

## 2.1. គោលបំណង

"ការពារប្រជាពលរដ្ឋកម្ពុជា ការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយផលប៉ះពាល់សង្គម-សេដ្ឋកិច្ច ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនអ្នកឆ្លង, អ្នកជំងឺសម្រាកពេទ្យ និងស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩" ។

## 2.2. គោលដៅ

"កាត់បន្ថយការឆ្លង ភាពធ្ងន់ធ្ងរនៃជំងឺ និងស្លាប់ ដែលបណ្តាលមកពីជំងឺកូវីដ-១៩ និងទប់ទល់នឹងការគម្រាមកំហែងនៃមេរោគបំលែងខ្លួនថ្មីៗ ជាពិសេសមេរោគប្រភេទដែលតា តាមរយៈការផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារនិងយុវវ័យអាយុពី១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ ដែលមានចំនួនប្រមាណ ២ លាននាក់ នៅដំណាច់ខែវិច្ឆិកា ឆ្នាំ២០២១"

គោលដៅខាងលើនេះនឹងត្រូវបានវាស់វែង តាមរយៈសូចនាករខាងក្រោម៖

- >៩០% នៃកុមារ-យុវវ័យ-បានចាក់វ៉ាក់សាំងពេញលេញ (របបវ៉ាក់សាំងចាក់ ២ដូស)
- ៧៥% នៃប្រជាជនកម្ពុជាសរុបប្រមាណ ១៦លាននាក់ ត្រូវបានគ្របដណ្តប់នៃវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ (សូមមើលរូបភាព ២.១)។

## 2.3. គោលការណ៍នៃចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩

### (១) ការស្ម័គ្រចិត្ត និងមិនបង់ថ្លៃ

រាជរដ្ឋាភិបាលនឹងផ្តល់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារ-យុវវ័យ គ្រប់រូប តាមគោលការណ៍ស្ម័គ្រចិត្ត និងមិនបង់ថ្លៃ។ ទោះបីការចាក់វ៉ាក់សាំងឈរគោលការណ៍ស្ម័គ្រក៏ដោយ ក៏រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យមាតា-បិតា និងអាណាព្យាបាលនាំបុត្រ-ធីតា ឬកូន-ក្មួយដែលមានកុមារ-យុវវ័យ ទៅចាក់វ៉ាក់សាំងឱ្យបានគ្រប់ៗគ្នា តាមកាលកំណត់របស់ គ.វ.ក-១៩ និងអនុ-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរាជធានី-ខេត្ត។ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ អាចជួយការពារកុមារ-យុវវ័យ និងការពារគ្រួសារពីការឆ្លងជំងឺកូវីដ-១៩ និងជួយកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ ឬគ្រោះថ្នាក់ដល់អាយុជីវិត ក្នុងករណីឆ្លងជំងឺកូវីដ-១៩។

**រូបភាព ២.១.** និន្នាការនៃការគ្របដណ្តប់នៃវ៉ាក់សាំងលើក្រុមប្រជាជនជាគោលដៅ ១២លាននាក់




### (២) សុវត្ថិភាព និងប្រសិទ្ធភាព

វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា គឺជាប្រភេទវ៉ាក់សាំងដែលស្ថិតក្នុង «បញ្ជីវ៉ាក់សាំងដែលអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាបន្ទាន់» របស់អង្គការសុខភាពពិភពលោក និងជាប្រភេទវ៉ាក់សាំងដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀត សុវត្ថិភាព និងប្រសិទ្ធភាព ក៏សំដៅផងដែរទៅលើទិដ្ឋភាពសំខាន់ ៣ យ៉ាងផ្សេងទៀត៖ (**ទី១.**) ការរក្សាប្រព័ន្ធត្រជាក់ថែរក្សាវ៉ាក់សាំងតាមបទដ្ឋានស្តង់ដារ និងសន្តិសុខវ៉ាក់សាំងនៅមណ្ឌលស្តុកវ៉ាក់សាំង ពេលដឹកជញ្ជូនចែកចាយ និងពេលកំពុងដំណើរការចាក់វ៉ាក់សាំងនៅតាមទីតាំងចាក់វ៉ាក់សាំង, (**ទី២.**) រក្សាអនុលោមភាព តាមពិធីសារបច្ចេកទេសនៃការចាក់វ៉ាក់សាំង និងការគ្រប់គ្រង

កាកសំណល់ក្រោយការចាក់វ៉ាក់សាំង និង (**ទី៣.**) ការពង្រឹងវិធានការសុខាភិបាល (ពាក់ម៉ាស គម្លាតបុគ្គល អនាម័យដៃ/ផ្លូវដង្ហើម) និងរក្សាអនាម័យល្អនៅក្នុងទីតាំងចាក់វ៉ាក់សាំងជាប់ជាប្រចាំ ដើម្បីជៀសវាងឱ្យបាននូវការចម្លងនៃជំងឺកូវីដ-១៩ និងធានាថាទីតាំងនៃការចាក់វ៉ាក់សាំងមិនក្លាយជាប្រភពនៃការចម្លងជំងឺកូវីដ-១៩។

## (៣) ប្រើប្រាស់ធនធានហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់

កិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃដំណើរការចាក់វ៉ាក់សាំងជុំទីមួយ។ រហូតដល់ពេលនេះ ធនធានហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដែលបម្រើឱ្យការងារចាក់វ៉ាក់សាំង រួមមានជាអាទិ៍៖ ប្រព័ន្ធ យន្តការ និងសេវាគាំទ្រចាំបាច់នានា ការបណ្តុះ-បណ្តាល ធនធានមនុស្ស និងឧបករណ៍បច្ចេកទេសនានា ត្រូវបានពិនិត្យ/បច្ចុប្បន្នកម្ម និងកែលម្អឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់។ ដូច្នេះ គ.វ.ក-១៩ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរាជធានី-ខេត្ត និងមូលដ្ឋានសុខាភិបាល ត្រូវសម្របសម្រួលការប្រើប្រាស់ធនធានហេដ្ឋារចនាសម្ព័ន្ធទាំងអស់នោះឱ្យអស់លទ្ធភាព សម្រាប់កិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ។

## (៤) រក្សានិរន្តភាពនៃការផ្តល់សេវាសុខភាពសារវ័ន្តជាប្រចាំ

កិច្ចដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារនិងយុវវ័យ នឹងប្រព្រឹត្តទៅស្របពេលគ្នាជាមួយនឹងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើប្រជាពលរដ្ឋអាយុចាប់ពី១៨ ឆ្នាំឡើង។ ក្នុងបរិការណ៍នេះ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវរៀបចំចាត់ចែងគ្រូពេទ្យ បុគ្គលិកបច្ចេកទេសសុខាភិបាល និងបុគ្គលិកគាំទ្រផ្សេងទៀតៗ ឱ្យបានសមស្រប ដើម្បីកុំឱ្យមានការរអាក់រអួលដល់ដំណើរការផ្តល់សេវាសុខភាពសារវ័ន្តជាប្រចាំ ជូនប្រជាពលរដ្ឋទូទៅផង និងរក្សាល្បឿននៃការចាក់វ៉ាក់សាំងឱ្យលឿនតាមដែលអាចធ្វើទៅបានផង ជាពិសេសនៅពេលដែលបរិមាណវ៉ាក់សាំងកាន់តែច្រើនត្រូវបានផ្គត់ផ្គង់ឱ្យ ក្នុងមួយលើកៗ។

## (៥) ការចូលរួមពីវិស័យឯកជន

មានការថារំពឹងថានៅក្នុងពេលខាងមុខនេះ ក្រុមហ៊ុនផលិតប្រភេទវ៉ាក់សាំងបានបង្កើនសមត្ថភាពផលិតរបស់ខ្លួន និងមានវ៉ាក់សាំងកូវីដ-១៩ ប្រភេទថ្មីៗ ថែមទៀតត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដូច្នេះបរិមាណនៃការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ នឹងកើនឡើងជាលំដាប់ទៅតាមពេលវេលា។ ក្នុងបរិការណ៍នេះ ក្រុមហ៊ុនឯកជនដែលមានច្បាប់អនុញ្ញាតិអាចមានលទ្ធភាពនាំចូល និងចែកចាយវ៉ាក់សាំង នៅក្នុងប្រទេសកម្ពុជា ដូច្នេះប្រជាពលរដ្ឋមានជម្រើស ក្នុងការទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ពីសេវាសុខាភិបាលឯកជនផងដែរ។

## 3. អភិក្រមនៃការចាក់វ៉ាក់សាំង

ជាទូទៅ អភិក្រម " **ផ្កាវីក**" ត្រូវបានប្រើប្រាស់ ជាអភិក្រមគោលនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារ-យុវវ័យ ខណៈពេលអន្តរាគមន៍ជាយុទ្ធសាស្ត្រដែលបានចែងនៅក្នុង ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស នៅតែជាគន្លឹះសម្រាប់រៀបចំ និងអនុវត្តផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ។ គួរបញ្ជាក់ឡើងវិញថា ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារ-យុវវ័យ នឹងប្រព្រឹត្តទៅក្នុងពេលវេលាជាមួយគ្នានឹងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទីមួយ។

### 3.1 វិធីសាស្ត្រចម្រុះបត់បែន

វិធីសាស្ត្រចម្រុះបត់បែន ជាវិធីសាស្ត្រ "ឆ្លាស់គ្នា" រវាង "នីតិវិធីចាក់ព្រមគ្នា" និង "នីតិវិធីចាក់បន្តគ្នា" រវាងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារ-យុវវ័យ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ។ គួរបញ្ជាក់ថា ទោះបីប្រើប្រាស់នីតិវិធីណាមួយក៏ដោយ ក៏ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ ត្រូវចាប់ផ្តើមចេញដំណើរពីរាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តព្រះសីហនុ និងខេត្តកោះកុង។ ការកំណត់ក្រុង-ស្រុក-ខណ្ឌ នៃខេត្តផ្សេងទៀត ដែលត្រូវដំណើរការចាក់វ៉ាក់សាំងក្នុងជំហាននិមួយៗ ត្រូវផ្អែកតាមលក្ខណៈវិនិច្ឆ័យខាងក្រោម៖

(១)បរិមាណវ៉ាក់សាំងដែលត្រូវបានផ្គត់ផ្គង់មួយលើកៗ ដល់រាជធានី-ខេត្តនិមួយៗ

(២)ក្រុង-ស្រុក-ខណ្ឌ ដែលត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ-១៩ និង

(៣)ក្រុង-ស្រុក-ខណ្ឌមានដង់ស៊ីតេប្រជាជនច្រើន (ទីប្រជុំជនធំៗមានប្រជាជនរស់នៅកុះករ និងមានសក្តានុពលផ្នែកសង្គម-សេដ្ឋកិច្ច(ប្រមូលផ្តុំដោយរោងចក្រ-សហគ្រាស) និងផ្នែកទេសចរណ៍ (ជាលក្ខណៈវិនិច្ឆ័យសម្រាប់នីតិវិធីទាំងពីរ)។

**(១) នីតិវិធីចាក់ព្រមគ្នា**

នីតិវិធីចាក់ព្រមគ្នាសំដៅដល់ ដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ ដែលប្រព្រឹត្តទៅទន្ទឹមគ្នាតែម្តងជាមួយនឹងការចាក់វ៉ាក់សាំងបង្ការជំងឺ-១៩ជុំទី១(ប្រជាជនអាយុពី១៨ឆ្នាំឡើង) **នៅពេលមានវ៉ាក់សាំងសម្រាប់ប្រជាពលរដ្ឋក្នុងជុំទី១ ផង និងលើកុមារ-យុវវ័យផង** ដោយមិនរង់ចាំរហូតដល់ពេលដែលខេត្តនិមួយៗ បញ្ចប់ការចាក់វ៉ាក់សាំងជុំទី១ ក្នុងខេត្តរបស់ខ្លួន។ នីតិវិធីនេះ ប្រហែលជាអាចត្រូវការក្រុមការងារចាក់វ៉ាក់សាំងបន្ថែម ឬបង្កើនសមត្ថភាពស្តុកវ៉ាក់សាំង និងប្រព័ន្ធត្រជាក់រក្សា

វ៉ាក់សាំងនៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត ឬនៅតាមទីតាំងចាក់វ៉ាក់សាំង។ ដូច្នេះមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវពិនិត្យមើលធនធានហេដ្ឋារចនាសម្ព័ន្ធដែលមានបច្ចុប្បន្ន និងកៀងគរធនធានបន្ថែមត្រៀមទុកជាមុន ដើម្បីធានាឱ្យយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដំណើរការទៅមុខដោយរលូនតាមផែនការដែលបានកំណត់។

**(២) នីតិវិធីចាក់បន្តគ្នា**

នីតិវិធីចាក់បន្តគ្នា សំដៅដល់ដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បន្តតាមក្រុមគោលដៅនិមួយៗ **នៅពេលដែលវ៉ាក់សាំងមានសម្រាប់តែក្រុមគោលដៅណាមួយ** ហើយនៅពេលដែលមានវ៉ាក់សាំងសម្រាប់ប្រជាពលរដ្ឋក្នុងជុំទី១ផង និងកុមារ-យុវវ័យផង នីតិវិធីចាក់បន្តនេះត្រូវប្តូរមកនីតិវិធីចាក់ព្រមគ្នាវិញ។ គួរកត់សម្គាល់ថា នីតិវិធីចាក់បន្តគ្នាប្រហែលជាមិនត្រូវការធនធានបន្ថែមទេ ដូចជាចំនួនក្រុមការងារចាក់វ៉ាក់សាំង ឬការបង្កើនសមត្ថភាពស្តុកវ៉ាក់សាំង/ប្រព័ន្ធត្រជាក់។

## 3.2 នីតិវិធីដើម្បីទទួលបានការចាក់វ៉ាក់សាំង

**(១) ការអនុញ្ញាតឱ្យចាក់វ៉ាក់សាំង៖** កុមារ-យុវវ័យ ដែលត្រូវបានអនុញ្ញាតឱ្យចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវបំពេញតាមលក្ខខណ្ឌដូចបានកំណត់ខាងក្រោមនេះ៖

ក. កុមារ-យុវវ័យ ត្រូវមានអាយុ **គ្រប់ ១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ** នៅថ្ងៃដែលមកចាក់វ៉ាក់សាំង

ខ. កុមារ-យុវវ័យ ដែលត្រូវបានអនុញ្ញាតិឱ្យចាក់វ៉ាក់សាំងកូវីដ-១៩ បាន ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីមាតា-បិតា ឬអាណាព្យាបាលតាមផ្លូវច្បាប់របស់ខ្លួន (បន្ទាប់ទៅនេះហៅថា *អាណាព្យាបាល*)។ មាតា-បិតា ឬអាណាព្យាបាលអាចទាញយកគំរូលិខិតយល់ព្រមអនុញ្ញាតិឱ្យចាក់វ៉ាក់សាំងកូវីដ-១៩ ចេញពីគេហទំព័រ www.vaccine.gov.kh របស់ គ.វ.ក-១៩។

គ. ចំពោះកុមារ-យុវវ័យដែលកំពុងរស់នៅ ធ្វើការ ឬរៀនសូត្រនៅពេលបច្ចុប្បន្ន នៅក្នុងខេត្តផ្សេងក្រៅពីខេត្តដែលឪពុក-ម្តាយ ឬអាណាព្យាបាលកំពុងរស់នៅ ឪពុក-ម្តាយ ឬអាណាព្យាបាលត្រូវបំពេញលិខិតយល់ព្រមអនុញ្ញាតិឱ្យចាក់វ៉ាក់សាំង (លិខិតសរសេរដៃ យកតាមគំរូលិខិតយល់ព្រមអនុញ្ញាតិ របស់ គ.វ.ក-១៩) មកកូន-ក្មួយ របស់ខ្លួនឱ្យបានមុនថ្ងៃចាក់វ៉ាក់សាំង។

ឃ.កុមារ-យុវវ័យកំព្រាឪពុក-ម្តាយ ឬគ្មានអាណាព្យាបាល ដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច ឬដោយអង្គការផ្សេងៗ ត្រូវបានការយល់ព្រមពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ឬពីអង្គការនោះ អនុលោមតាមអំណាចច្បាប់ដែលមានប្រគល់ឱ្យ។

ង. កុមារ-យុវវ័យកំព្រាដែលគ្មានទីពឹង និងគ្មានផ្ទះសម្បែងរស់នៅពិតប្រាកដ អាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋាន ត្រូវទទួលខុសត្រូវក្នុងការប្រមូលក្រុមនេះមកចាក់វ៉ាក់សាំង។

ច. នៅថ្ងៃមកចាក់វ៉ាក់សាំង មាតា-បិតា ឬអាណាព្យាបាលរបស់កុមារ-យុវវ័យ ត្រូវបង្ហាញ ឬបំពេញលិខិតយល់ព្រមអនុញ្ញាតឱ្យចាក់វ៉ាក់សាំង ដល់មន្ត្រីគ្រប់គ្រងទីតាំងចាក់វ៉ាក់-សាំង។ នៅថ្ងៃមកចាក់វ៉ាក់សាំង មាតា-បិតា ឬអាណាព្យាបាលរបស់កុមារ-យុវវ័យ ត្រូវបង្ហាញ ឬបំពេញលិខិតយល់ព្រមអនុញ្ញាតិឱ្យចាក់វ៉ាក់សាំង ដល់មន្ត្រីគ្រប់គ្រងទីតាំងចាក់វ៉ាក់សាំង។ ចំពោះ យុវវ័យដូចបានចែងក្នុងចំណុច គ ខាងលើ ក៏ត្រូវបង្ហាញលិខិតយល់ព្រមអនុញ្ញាតិឱ្យចាក់វ៉ាក់សាំងកូវីដ-១៩ របស់ឪពុក-ម្តាយ ឬអាណាព្យាបាលដល់មន្ត្រីគ្រប់គ្រងទីតាំងចាក់វ៉ាក់-សាំង ផងដែរ។

ឆ. នៅមុនពេលចាក់វ៉ាក់សាំង កុមារ-យុវវ័យ ត្រូវបានពិនិត្យសុខភាពយ៉ាងម៉ត់ចត់ និងត្រូវបានអនុញ្ញាតឱ្យចាក់ដោយគ្រូពេទ្យនៅទីតាំងចាក់វ៉ាក់សាំង។ ដូច្នេះ ឪពុក-ម្តាយ ឬអាណា-ព្យាបាល ត្រូវបញ្ជាក់ប្រាប់អំពីលក្ខខ័ណ្ឌសុខភាពរបស់កុមារ-យុវវ័យ ឱ្យបានច្បាស់ដល់គ្រូពេទ្យដែលមានភារៈកិច្ចពិនិត្យសុខភាពកុមារ-យុវវ័យនៅទីតាំងចាក់វ៉ាក់សាំង ឬក៏សុំការប្រឹក្សាយោបល់លើបញ្ហាសំខាន់ៗ ផ្សេងទៀតៗ ដែលទាក់ទងនឹងចាក់វ៉ាក់សាំងនេះ។

(២) **ការចុះឈ្មោះចាក់វ៉ាក់សាំងទុកជាមុន៖** មាតា-បិតា ឬអាណាព្យាបាល ត្រូវចុះឈ្មោះកុមារ-យុវវ័យត្រូវចាក់វ៉ាក់សាំងទុកជាមុន នៅក្នុងគេហទំព័រ www.vaccine.gov.kh។ យោងតាមស្ថានភាពជាក់ស្តែង អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាចជួយរៀបចំបញ្ជីឈ្មោះកុមារ-យុវវ័យ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន និងដោយមានការយល់ព្រមពីមាតា-បិតា ឬអាណាព្យាបាលរបស់កុមារ-យុវវ័យទាំងនោះ រួចចុះឈ្មោះឱ្យទុកជាមុននៅក្នុងគេហទំព័រ www.vaccine.gov.kh ឬបញ្ជូនបញ្ជីឈ្មោះនោះទៅមន្ត្រីគ្រប់គ្រងទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលស្ថិតនៅជិតបំផុត។

## 3.3 ការកំណត់ និងការរៀបចំទីតាំងចាក់វ៉ាក់សាំង

- **នៅមូលដ្ឋានសុខាភិបាលសាធារណៈ៖** ការផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យនឹងប្រព្រឹត្តទៅនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ នៅតាមរាជធានី-ខេត្ត រួមមានជាអាទិ៍ មន្ទីរ-ពេទ្យជាតិ មន្ទីរពេទ្យបង្អែករាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ និងមណ្ឌលសុខភាព ដែលត្រូវបានកំណត់ដោយរដ្ឋបាលរាជធានី-ខេត្ត។
- **នៅទីតាំងចល័ត៖** គ្រឹះស្ថានសិក្សាសាធារណៈ ជាទីតាំងមួយដែលអំណោយផល ដល់ការពង្រឹងវិធានការ «៣ ការពារ ៣ កុំ» ។ ការជ្រើសរើសយកគ្រឹះស្ថានសិក្សា ធ្វើជាទីតាំងចាក់វ៉ាក់សាំង

បង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ អាស្រ័យលើការសម្រេចរបស់រដ្ឋបាលរាជធានី-ខេត្ត ទៅតាមស្ថានភាពជាក់ស្តែងរបស់រាជធានី-ខេត្ត និមួយៗ ។ គួរកត់សម្គាល់ថា គ្រឹះស្ថានសិក្សាដែលត្រូវបានជ្រើសរើសជាទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ ត្រូវមានទីធ្លាធំទូលាយ និងស្ថិតនៅជិតមន្ទីរពេទ្យ ដើម្បីផ្តល់សេវាសង្គ្រោះបន្ទាន់ទាន់ពេលវេលា ចំពោះផលវិបាកណាមួយដែលអាចកើតមានជាយថាហេតុ បន្ទាប់ពីការចាក់វ៉ាក់សាំង។

ការរៀបចំទីតាំងចាក់វ៉ាក់សាំង និងវិហូរនៃកិច្ចដំណើរការចាក់វ៉ាក់សាំង ត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំបច្ចេកទេស និងនិតិវិធីដែលបានកំណត់។ នៅតាមទីតាំងចាក់វ៉ាក់សាំងត្រូវរៀបចំឱ្យមានគំនូសបំព្រួញបង្ហាញផ្លូវ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកមកចាក់វ៉ាក់សាំង និងមានផ្ទាំងរូបភាពអប់រំណែនាំខ្លីៗ ដែលអ្នកមកចាក់វ៉ាក់សាំង ងាយស្រួលមើលឃើញ ខណៈពេលអង្គុយរង់ចាំ។

## 3.4 ក្រុមការងារចាក់វ៉ាក់សាំង

ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈក្តី និង/ឬ នៅតាមទីតាំងចល័តក្តី ត្រូវធ្វើឡើងដោយក្រុមការងារចាក់វ៉ាក់សាំងដែលជាគ្រូពេទ្យ-បុគ្គលិកសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរពេទ្យជាតិ។ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត គប្បីពិនិត្យមើល និងកំណត់ឡើងវិញនូវចំនួនទីតាំងចាក់វ៉ាក់សាំង ព្រមទាំងចំនួនក្រុមការងារចាក់វ៉ាក់សាំងឱ្យបានសមស្រប នៅតាមរាជធានី-ខេត្តសាម៉ី សំដៅធានាឱ្យដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទីមួយ ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពខ្ពស់ មានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ ទប់ស្កាត់បានការឆ្លងជំងឺកូវីដ-១៩ និងបានលឿនតាមដែលអាចធ្វើទៅបាន។

## 3.5 ការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

**គ.វ.ក-១៩** ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវវ័យ តាមរយៈការរៀបចំផែនការសកម្មភាពចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមដានត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់ការអនុវត្តផែនការសកម្មភាពចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងក្របខ័ណ្ឌនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទូទាំងប្រទេស ។

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ រាជធានី-ខេត្ត ត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩សម្រាប់កុមារ-យុវវ័យ និងតាមដានត្រួតពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តផែនការ និងដោះស្រាយបញ្ហាប្រឈម

នានាដែលជួបប្រទះ ឱ្យបានទាន់ពេលវេលា នៅក្នុងក្របខ័ណ្ឌនៃយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទូទាំងរាជធានី-ខេត្ត។

## 3.6 ការគ្រប់គ្រងវ៉ាក់សាំង និងសំណល់ក្រោយការចាក់វ៉ាក់សាំង

ការគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់វ៉ាក់សាំង/សម្ភារៈបរិក្ខារ នឹងប្រព្រឹត្តទៅតាមប្រព័ន្ធ និងយន្តការដែលកំពុងមានស្រាប់ ដែលផ្តោតជាចម្បងលើ៖

- ការងារគ្រប់គ្រង និងបែងចែកវ៉ាក់សាំងនិងសម្ភារៈបរិក្ខារ ការគ្រប់គ្រងប្រព័ន្ធត្រជាក់ដើម្បីថែរក្សាសុវត្ថិភាព និងប្រសិទ្ធភាពវ៉ាក់សាំង។
- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំងឱ្យបានត្រឹមត្រូវ ធ្វើបច្ចុប្បន្នភាពបញ្ជីស្តុកវ៉ាក់សាំង ចំនួនវ៉ាក់សាំងប្រើប្រាស់និងនៅសល់ប្រចាំថ្ងៃ និងរាយការណ៍ទៀងទាត់តាមកាលកំណត់។
- ការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងបានត្រឹមត្រូវ ដូចជា ម្ជុល សេរ៉ាំង ជាដើម ដើម្បីការរក្សាបរិស្ថានអនាម័យល្អ និងបង្ការការឆ្លងរោគ តាមរយៈការអនុវត្ត «គោលការណ៍ណែនាំជាតិស្តីពីសុវត្ថិភាពចាក់ថ្នាំបង្ការ និងការគ្រប់គ្រងសំណល់ និងប្រព័ន្ធបោះចោលសំរាមសម្រាប់កម្មវិធីចាក់ថ្នាំបង្ការ» ។

## 3.7 ការអប់រំផ្សព្វផ្សាយដល់សាធារណៈជន និងតាមដានផលរំខានក្រោយការចាក់វ៉ាក់សាំង

